# សាររបស់ប្រធានប្រតិបត្តិ នៃ សហព័ន្ធខ្មែរកម្ពុជាក្រោម
# ក្នុងពិធីខួប ១៦ ឆ្នាំ
# ថ្ងៃអង្គការសហប្រជាជាតិអនុម័តសេចក្ដីប្រកាសស្ដីពីសិទ្ធិជនជាតិដើម
**(១៣ កញ្ញា ២០០៧ - ១៣ កញ្ញា ២០២៣)**

*ថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ ២០២៣*

សូមគោរពចំពោះថ្នាក់ដឹកនាំ សមាជិក សមាជិកា និងអ្នកគាំទ្រ សហព័ន្ធខ្មែរកម្ពុជាក្រោម ព្រមទាំងជនរួមជាតិទាំងអស់ជាទីមេត្រីៗ ។

ក្នុងនាមប្រធានប្រតិបត្តិ នៃ សហព័ន្ធខ្មែរកម្ពុជាក្រោម ខ្ញុំសូមនិយាយអំពីបញ្ហាសំខាន់មួយដែលមានអត្ថន័យជ្រាលជ្រៅទាក់ទងនឹងបេសកកម្មរួមរបស់យើង និងគុណតម្លៃជាចំណែកមួយនៃចលនាតតស៊ូរបស់យើង ។

បច្ចុប្បន្ន យើងនៅតែមានក្ដីព្រួយបារម្ភអំពីការចាប់ខ្លួន និងដាក់គុកសកម្មជនសិទ្ធិមនុស្សខ្មែរក្រោមដ៏ក្លាហានរបស់យើងទាំង ៤ រូប ដូចជា លោក **ថាច់ កឿង**, លោក **តោ ហ្វាង ចឿង**, លោក **យ៉ាញ មិញ ក្វាង**, និងអ្នកស្រី **ឌិញ ធី វិន** ។ ការដែលរដ្ឋាភិបាលវៀតណាមចាប់ខ្លួនពួកគាត់នោះ ដោយសារតែពួកគាត់បាននាំគ្នាថតចម្លង និងចែកចាយឯកសារសំខាន់ៗរបស់អង្គការសហប្រជាជាតិ ដូចជា សេចក្ដីប្រកាសស្ដីពីសិទ្ធិជនជាតិដើម (UNDRIP) និងសិទ្ធិមនុស្ស ព្រមទាំងរៀបចំពិធីអបអរសាទរទិវាអន្តរជាតិនានា ដើម្បីលើកកម្ពស់សិទ្ធិមនុស្ស និងសិទ្ធិជនជាតិដើមរបស់ខ្លួន ក្នុងនោះមាន «ទិវានារីអន្តរជាតិ» , «ទិវាសិទ្ធិមនុស្សអន្តរជាតិ ១០ ធ្នូ» និង «ថ្ងៃអង្គការសហប្រជាជាតិអនុម័តសេចក្ដីប្រកាសសិទ្ធិជនជាតិដើម ១៣ កញ្ញា» ជាដើម ។ ឥឡូវនេះពួកគាត់កំពុងត្រូវប្រឈមនឹងការធ្វើទុក្ខបុកម្នេញពីរដ្ឋាភិបាលវៀតណាម ទោះបីវៀតណាមជាសមាជិក នៃ ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិយ៉ាងណាក៏ដោយ ។

នៅពេលដែលជនជាតិដើមលើពិភពលោករួមគ្នា ប្រារព្ធពិធីអបអរសាទរថ្ងៃអង្គការសហប្រជាជាតិអនុម័តសេចក្ដីប្រកាសស្ដីពីសិទ្ធិជនជាតិដើម (UNDRIP) វាជាឱកាសដ៏ល្អមួយ ដើម្បីឆ្លុះបញ្ចាំងពីសារៈសំខាន់ដ៏ជ្រាលជ្រៅនៃសេចក្ដីប្រកាសនេះសម្រាប់ជនជាតិដើមខ្មែរក្រោម ដែលត្រូវគេបិទសំឡេងនៅលើមាតុភូមិកម្ពុជាក្រោមរបស់យើង ។ ក្រៅពីនេះ យើងសូមគូសបញ្ជាក់អំពីមូលហេតុដែលខ្មែរក្រោមត្រូវតែត្រូវបានទទួលស្គាល់ជាផ្លូវការថាជា «ជនជាតិដើម» នៅលើទឹកដីកម្ពុជាក្រោម ដោយមិនត្រូវប្រឈមមុខនឹងការដាក់ទណ្ឌកម្មចំពោះការតស៊ូមតិ ដើម្បីសិទ្ធិជនជាតិដើមរបស់ខ្លួនឡើយ ។

ការអនុម័តសេចក្ដីប្រកាសស្ដីពីសិទ្ធិជនជាតិដើម គឺជាព្រឹត្តិការណ៍ដ៏សំខាន់មួយសម្រាប់ជនជាតិដើមខ្មែរក្រោម និងជនជាតិដើមនៅទូទាំងពិភពលោក ។ ខាងក្រោមនេះគឺជាហេតុផលចម្បងមួយចំនួនដែល

បញ្ជាក់ថា ហេតុអ្វីបានជា «សេចក្តីប្រកាសស្តីពីសិទ្ធិជនជាតិដើម» មានតម្លៃមិនអាចកាត់ថ្លៃបានសម្រាប់ប្រជាជាតិខ្មែរក្រោមរបស់យើង៖

- បង្កើតក្របខណ្ឌសកល នៃស្តង់ដារអប្បបរមាសម្រាប់ការពារការរស់រានមានជីវិត សេចក្តីថ្លៃថ្នូរ និងសុខុមាលភាពរបស់ជនជាតិដើម ។ វាផ្អែកលើស្តង់ដារសិទ្ធិមនុស្សដែលមានស្រាប់ និងសេរីភាពជាមូលដ្ឋាន ដោយពង្រឹងការអនុវត្តរបស់ពួកគេចំពោះក្រុមជនជាតិដើម ។
- លើសពីធម្មនុញ្ញសិទ្ធិមនុស្សផ្សេងទៀត ដោយការការពារសិទ្ធិសមូហភាព និងបុគ្គល ដោយផ្តល់នូវការការពារយ៉ាងទូលំទូលាយ ។
- បញ្ជាក់យ៉ាងច្បាស់អំពី «សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង» ។ ប្រការនេះ រាប់បញ្ចូលទាំងសិទ្ធិសំខាន់ក្នុងការផ្តល់ ឬបដិសេធការយល់ព្រមលើគម្រោង ដែលអាចប៉ះពាល់ដល់ទឹកដីជនជាតិដើម ។
- តាមរយៈការអនុម័ត «សេចក្តីប្រកាសស្តីពីសិទ្ធិជនជាតិដើម» ពិភពលោកនឹងមានការទទួលស្គាល់នូវភាពខុសគ្នា និងគោរពនូវភាពស្មើគ្នារបស់ជនជាតិដើម ដូចជាជាតិសាសន៍នានាក្នុងពិភពលោកដែរ ។

សម្រាប់ខ្មែរក្រោមរបស់យើង ការប្រារព្ធពិធីអបអរសាទរ «សេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើម» នោះ វាមានន័យដូចនឹងការអបអរសាទរចំពោះការបង្ហាញនូវអត្តសញ្ញាណ, សិទ្ធិ និងវត្តមានជាសកលរបស់យើង ។ វាបញ្ជាក់អំពីសិទ្ធិរបស់យើងពីកំណើត និងការបោះជំហានឆ្ពោះទៅរកការធានាក្នុងការរស់រានមានជីវិត សេចក្តីថ្លៃថ្នូរ និងសុខុមាលភាពរបស់យើង ។

ជាងនេះទៅទៀត ការទទួលស្គាល់ខ្មែរក្រោមជាជនជាតិដើមនៅដែនដីកម្ពុជាក្រោម មានអត្ថន័យយ៉ាងជ្រាលជ្រៅ៖

- ពលរដ្ឋខ្មែរក្រោមមានមរតកវប្បធម៌ដ៏សម្បូរបែបឆ្លងកាត់ជាច្រើនដំណាក់កាល នៃប្រវត្តិសាស្រ្ត ។ វប្បធម៌របស់យើងមានទំនាក់ទំនងយ៉ាងស៊ីជម្រៅជាមួយទឹកដីកម្ពុជាក្រោម ដែលមានវត្តជិត ៥០០ បានកសាងពាសពេញទឹកដីដូនតារបស់យើង ។ ការទទួលស្គាល់ខ្មែរក្រោមជាជនជាតិដើម គឺជាឧបករណ៍មួយក្នុងការថែរក្សាកេរដំណែលវប្បធម៌រូបីទាំងនេះសម្រាប់មនុស្សជំនាន់ក្រោយ ។
- ការទទួលស្គាល់គឺជាកត្តាសំខាន់ក្នុងការការពារសិទ្ធិរបស់ខ្មែរក្រោម ។ ខ្មែរក្រោមបានជួបប្រទះនឹងការរឹតត្បិតយ៉ាងធ្ងន់ធ្ងរលើផ្នែកផ្សេងៗ រួមទាំងសេរីភាពនៃការបញ្ចេញមតិ ការជួបជុំគ្នា ការបង្កើតសមាគម សារព័ត៌មាន និងចលនា ។ ខ្មែរក្រោមត្រូវតែទទួលបានការការពារពិសេសក្រោមច្បាប់អន្តរជាតិក្នុងនាមជាជនជាតិដើម ។

- ពលរដ្ឋខ្មែរក្រោមមានប្រវត្តិសាស្ត្រជាប់ទាក់ទងនឹងទឹកដីកម្ពុជាក្រោមជាច្រើនសតវត្សមកហើយ ។ ភាពពាក់ព័ន្ធប្រវត្តិសាស្ត្ររបស់យើងគឺមិនអាចប្រកែកបានឡើយ ហើយការទទួលស្គាល់ខ្មែរក្រោមជាជនជាតិដើម គឺជាកាយវិការនៃការគោរពចំពោះទំនាក់ទំនងប្រវត្តិសាស្ត្ររបស់យើងចំពោះទឹកដីនេះ និងការរួមចំណែកយ៉ាងសំខាន់របស់យើងចំពោះប្រវត្តិសាស្ត្រនៃទឹកដីកម្ពុជាក្រោម ។
- ការទទួលស្គាល់ខ្មែរក្រោមថាជាជនជាតិដើម គឺជាការជំរុញឲ្យមានភាពចម្រុះ ។ វាធ្វើឱ្យមានសុពលភាពនូវវប្បធម៌ និងប្រពៃណីពិសេសរបស់យើង និងជាការលើកកម្ពស់ការយល់ដឹង និងការគោរពគ្នាទៅវិញទៅមកក្នុងចំណោមក្រុមជនជាតិចម្រុះ ។ ប្រការនេះ ជាការត្រួសត្រាយផ្លូវសម្រាប់សង្គមមួយដែលរស់នៅរួមគ្នាបានប្រកបដោយសេចក្ដីស្រឡាញ់ និងលើកកម្ពស់ចំពោះខឿនវប្បធម៌ដ៏សម្បូរបែបរបស់យើង ។

សំខាន់បំផុត ការទទួលស្គាល់ខ្មែរក្រោមជាជនជាតិដើមនៃទឹកដីកម្ពុជាក្រោម មិនមែនគ្រាន់តែជាការទទួលស្គាល់ទំនាក់ទំនងប្រវត្តិសាស្ត្ររបស់យើងចំពោះទឹកដីនេះតែប៉ុណ្ណោះទេ តែវាជាការការពារនូវបេតិកភណ្ឌវប្បធម៌, ការការពារសិទ្ធិ, ការលើកកម្ពស់ភាពចម្រុះ និងការធានានូវអនាគតរបស់យើង ។ វាគឺជាការលើកតម្កើងចំពោះអត្តសញ្ញាណពិសេស និងការរួមចំណែករបស់យើងអស់ចិរវេលាដ៏យូរលង់ចំពោះប្រវត្តិសាស្ត្ររួមរបស់យើង ។

ក្នុងនាមជារដ្ឋសមាជិកដែលបានអនុម័តលើ «សេចក្ដីប្រកាសរបស់អង្គការសហប្រជាជាតិស្ដីពីសិទ្ធិជនជាតិដើម» ឥឡូវនេះ វៀតណាមត្រូវតែចាត់វិធានការចាំបាច់ ដើម្បីទទួលស្គាល់នូវស្ថានភាពជនជាតិដើមរបស់ខ្មែរក្រោម ជាពិសេសនៅកម្ពុជាក្រោម ។ ការធ្វើដូច្នេះស្របទៅនឹងកិច្ចខិតខំប្រឹងប្រែងជាសកលដើម្បីលុបបំបាត់ការរំលាយពូជសាសន៍ និងការគាបសង្កត់ ដើម្បីធានាឱ្យមានអនាគតភ្លឺស្វាង និងស្មើភាពជាងមុនសម្រាប់មនុស្សគ្រប់ជាតិសាសន៍ ។

ជាមួយនឹងការប្ដេជ្ញាចិត្តមិនផ្លាស់ប្ដូរ និងការប្ដេជ្ញាចិត្តដែលមិនអាចកាត់ថ្លៃបានចំពោះយុត្តិធម៌ សូមឲ្យយុត្តិធម៌មានសម្រាប់ខ្មែរក្រោម ដែលជាជនជាតិដើមនៃដែនដីកម្ពុជាក្រោម ។

ដោយសេចក្ដីគោរពរាប់អានដ៏ជ្រាលជ្រៅពីខ្ញុំព្រះករុណា ខ្ញុំបាទ ។

ហត្ថលេខា និងត្រា

**ថ្រាក់ សេរីវុឌ្ឍ**

**ប្រធានប្រតិបត្តិ នៃ សហព័ន្ធខ្មែរកម្ពុជាក្រោម**

(លិខិតនេះប្រែសម្រួលចេញពីច្បាប់ដើមភាសាអង់គ្លេស)